# សន្ទរកថា

## ក្នុងពិធីបើកសិក្ខាសាលាស្តីពីការផ្សព្វផ្សាយអំពីគោលការណ៍ណែនាំស្តីពីការប្រើប្រាស់ទម្រង់របាយការណ៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប្រព័ន្ធលំហូររបាយការណ៍ក្រោមក្របខណ្ឌផែនការអនុវត្តរយៈពេលបីឆ្នាំដំបូង

## សណ្ឋាគារភ្នំពេញ, ថ្ងៃទី០៤-០៥ ខែ តុលា ឆ្នាំ២០១១

**សូមគោរព :**

- លោក លោកស្រីដែលជាទីប្រឹក្សា និងមន្ត្រីនៃលេខាធិការដ្ឋាន គ.ជ.អ.ប
- លោក លោកស្រី តំណាងឱ្យអនុកម្មវិធីនានារបស់ ផ.អ.៣
- លោក លោកស្រី តំណាងឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងទីប្រឹក្សាតាមដាន និងត្រួតពិនិត្យរាជធានី ខេត្ត
- លោក លោកស្រី តំណាងឱ្យកម្មវិធីសិទ្ធិកុមារ នៃអង្គការយូនីសេហ្វ ប្រចាំរាជធានីភ្នំពេញ និងតាមតំបន់គោលដៅ **ជាទីគោរព !**

ក្នុងនាមលេខាធិការដ្ឋាន គ.ជ.អ.ប និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានសេចក្តីសោមនស្សរីករាយ និងសូមស្វាគមន៍អស់លោក លោកស្រី ដែលមានវត្តមាននៅក្នុងអង្គសិក្ខាសាលានេះ។ ទន្ទឹមនឹងនេះដែរ ខ្ញុំក៏សូមថ្លែងអំណរគុណដល់មន្ត្រី និងទីប្រឹក្សានៃផ្នែកតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប ដែលបានខិតខំប្រឹងប្រែង ក្នុងការរៀបចំសិក្ខាសាលានេះឡើង។

ឆ្លៀតនាឱកាសនេះ ខ្ញុំសូមរំលឹកពីប្រវត្តិនៃការអនុវត្តនយោបាយវិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់បន្តិច ហើយអស់លោក លោកស្រីពិតជាបានជ្រួតជ្រាបរួចមកហើយ កម្ពុជាយើងបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ចំនួនពីរដងរួចមកហើយ គឺលើកទី១ នៅខែកុម្ភៈ ឆ្នាំ២០០២ និងលើកទី២ នៅខែ មេសា ឆ្នាំ២០០៧ តាមរយៈច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០១។

អាជ្ញាធរមូលដ្ឋាន ដែលបានជ្រើសរើសឡើងតាមការបោះឆ្នោតនេះ គឺជាមធ្យោបាយសម្រាប់អនុវត្តការងារ តាមរយៈការផ្ទេរភាពជាម្ចាស់ពីរាជរដ្ឋាភិបាល ដើម្បីធានាឱ្យឃុំ សង្កាត់ជាតំណាងផលប្រយោជន៍សហគមន៍នៅមូលដ្ឋានរបស់ខ្លួន ដោយមានការឆ្លើយតប និងគណនេយ្យភាពចំពោះសហគមន៍នៅមូលដ្ឋាន។

ផ្អែកលើបទពិសោធនដ៏ជោគជ័យនៅថ្នាក់ឃុំ សង្កាត់ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល រាជរដ្ឋាភិបាលបានបោះជំហានទៅមុខក្នុងការកែទម្រង់រដ្ឋបាលគ្រប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិរួមមានរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌផងដែរ ។ជាក់ស្តែង ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាទាំងនេះត្រូវបានធ្វើឡើងនៅខែ ឧសភា ឆ្នាំ២០០៩ តាមរយៈក្របខណ្ឌច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨។ ដើម្បីអនុវត្តច្បាប់អង្គការនេះ កម្មវិធី

ជាតិរយៈពេល១០ឆ្នាំ(២០១០-២០១៩) ត្រូវបានរាជរដ្ឋាភិបាលអនុម័តកាលពីថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១០ ហើយផែនការអនុវត្តរយៈពេល៣ឆ្នាំ (ផអ៣) នៃកម្មវិធីជាតិ (២០១១-២០១៣) ក៏ត្រូវបានរៀបចំ និងចាប់ ផ្តើមអនុវត្តជាបណ្តើរៗ កាលពីខែមិនា ឆ្នាំ២០១១ ដោយផ្តោតជាសំខាន់ទៅនឹងការរៀបចំស្ថាប័ន និងប្រព័ន្ធរដ្ឋថ្នាក់ក្រោមជាតិ និងការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសថ្នាក់ក្រុង ស្រុក ។

ផែនការអនុវត្តរយៈពេល៣ឆ្នាំនេះ មានអនុកម្មវិធីចំនួន ៦ ដែលត្រូវអនុវត្តដោយស្ថាប័នចំនួន ៦ រួមមាន លេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសម្ព័ន្ធជាតិក្រុមប្រឹក្សាឃុំ សង្កាត់ ។

ចំពោះរចនាសម្ព័ន្ធ និងយន្តការគាំទ្រការគ្រប់គ្រងអនុកម្មវិធីនៅថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំរួចរាល់ហើយ ដើម្បីអនុវត្តផែនការសកម្មភាព និងថវិកាក្នុងក្របខណ្ឌ ផអ៣ ដែលបានកំណត់នៅក្នុងអនុស្សរណៈនៃការយោគយល់គ្នារវាងរាជធានី ខេត្ត និងលេខាធិការដ្ឋាន គ.ជ.អ.ប ។ ដើម្បីកត់ត្រាវឌ្ឍនភាពនៃការអនុវត្តសកម្មភាពទាំងនេះ លេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំនូវទម្រង់របាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីលទ្ធផលនៃសកម្មភាពទាំងនេះ ។ ការរាយការណ៍នេះ មិនមានអ្វីស្មុគស្មាញទេ ប៉ុន្តែបញ្ហាដែលលំបាកស្មុគស្មាញនោះ គឺការកត់ត្រានូវសកម្មភាពអភិវឌ្ឍស្ថាប័ន និងការអភិវឌ្ឍមូលដ្ឋាននានា ជាពិសេសការកត់ត្រាការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានន័យថារបាយការណ៍នៃការអនុវត្ត ផ.អ.៣ នៅថ្នាក់រាជធានី ខេត្ត គឺមិនមែនផ្តោតតែលើការអនុវត្តផែនការសកម្មភាព និងថវិកាតែមួយប៉ុណ្ណោះទេ ។

### លោក លោកស្រី ដែលជាសមាជិក សមាជិកា នៃអង្គសិក្ខាសាលា ជាទីគោរព !

គោលការណ៍ណែនាំនេះ គឺផ្តោតទៅលើការរៀបចំរបាយការណ៍រាជធានី ខេត្ត ជាពិសេសទម្រង់របាយការណ៍ និងប្រព័ន្ធលំហូររបាយការណ៍នៅក្រោមក្របខ័ណ្ឌ ផ.អ.៣ ។ តាមការពិតទៅ យើងមានឧបករណ៍ បច្ចេកទេស និងសម្ភារៈជាច្រើនទៀតដែលនឹងត្រូវបង្កើតឡើងសម្រាប់ប្រព័ន្ធតាមដាន និងវាយតម្លៃ មានលក្ខណៈជាស្ថាប័ន ដូចដែលបានកំណត់នៅក្នុងក្របខ័ណ្ឌតាមដាន និងវាយតម្លៃ នៃ ផ.អ.៣ ។ ប៉ុន្តែការងារនេះ នាំឱ្យមានភាពយឺតយ៉ាវក្នុងការបង្កើតឱ្យមានប្រព័ន្ធតាមដាន និងវាយតម្លៃសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ពីព្រោះបញ្ហាទាំងនេះ គឺជាបញ្ហាបច្ចេកទេសដែលមានលក្ខណៈស្មុគស្មាញ និងទាមទារឱ្យមានការសិក្សាពីគ្រោះយោបល់ឱ្យបានទូលំទូលាយ ដើម្បីធានាបាននូវប្រសិទ្ធភាព និងនិរន្តភាពនៃការអនុវត្តរបស់ស្ថាប័ននៅថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

ចំពោះថ្នាក់ជាតិវិញ លេខាធិការដ្ឋានបានបង្កើតគោលការណ៍ណែនាំស្តីពីការរៀបចំរបាយការណ៍ ផ.អ.៣ សម្រាប់អនុកម្មវិធីនីមួយៗ ហើយនៅក្នុងពេលជាមួយគ្នានេះដែររបាយការណ៍វឌ្ឍនភាព ផ.អ.៣ ប្រចាំត្រីមាស ត្រូវបានរៀបចំរួច

ហើយ ព្រមទាំងបានផ្ញើជូនស្ថាប័នអនុវត្តអនុវិកម្មវិធីនីមួយៗ ដើម្បីពិនិត្យ និងចូលរួមយោបល់កែសម្រួល។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏យើងខ្វះខាតនូវព័ត៌មានមួយផ្នែកពីការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ។

ជាមួយគ្នានេះដែរ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការផ្ទេរសមត្ថភាពពីសេវាគាំទ្រក្នុងការអភិវឌ្ឍសមត្ថភាពមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ និងសារៈសំខាន់នៃការផ្តល់ព័ត៌មានសម្រាប់អន្តរាគមន៍ និងការជួយគាំទ្រពីថ្នាក់ជាតិ លេខាធិការដ្ឋាននឹងរៀបចំឱ្យមានជាប្រព័ន្ធរបាយការណ៍សេវាគាំទ្រ (របាយការណ៍ទីប្រឹក្សា) ដែលជាផ្នែកមួយនៃប្រព័ន្ធតាមដាន និងវាយតម្លៃ នៃ ផ.អ.៣ ផងដែរ។

សិក្ខាសាលានាថ្ងៃនេះ មានគោលបំណង ដើម្បីផ្តល់ការណែនាំ និងរៀនសូត្រជាមួយគ្នាអំពីទម្រង់របាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប្រព័ន្ធលំហូររបាយការណ៍ក្រោមក្របខ័ណ្ឌ ផ.អ.៣។ មន្ត្រីមកពីទីចាត់ការផែនការ និងវិនិយោគរបស់រាជធានី ខេត្តដែលបានចូលរួមនៅក្នុងសិក្ខាសាលានេះ នឹងទទួលភារកិច្ចរៀបចំរបាយការណ៍របស់រាជធានី ខេត្តផង និងធ្វើការណែនាំបន្តអំពីទម្រង់របាយការណ៍ និងប្រព័ន្ធលំហូររបាយការណ៍នេះដល់អ្នកពាក់ព័ន្ធនានានៅថ្នាក់រាជធានី ខេត្ត ព្រមទាំងអ្នកពាក់ព័ន្ធនានានៅ ថ្នាក់ក្រុង ស្រុក ខណ្ឌ ក្នុងរាជធានី ខេត្តរបស់ខ្លួន។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសំណូមពរដល់លោក លោកស្រី ដែលមានវត្តមាននៅក្នុងសិក្ខាសាលានេះ ជាពិសេសមន្ត្រីដែលភារកិច្ចរៀបចំរបាយការណ៍ និងផ្សព្វផ្សាយបន្តដលអ្នកពាក់ព័ន្ធ ខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ចូលរួមពិភាក្សា និងពិគ្រោះយោបល់នូវបញ្ហាពុំច្បាស់លាស់ ដើម្បីមានមូលដ្ឋានក្នុងការរៀបចំរបាយការណ៍ និងការណែនាំបន្តដល់អ្នកពាក់ព័ន្ធនៅថ្នាក់រាជធានី ខេត្តរបស់ខ្លួន ឱ្យទទួលបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់។

ជាទីបញ្ចប់ ក្នុងនាមលេខាធិការដ្ឋាន គ.ជ.អ.ប និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក លោកស្រីទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចូលរួមសិក្ខាសាលានេះ និងសូមប្រសិទ្ធិពរជ័យជូនលោក លោកស្រីទាំងអស់ ឱ្យទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាងឃ្លាតឡើយ និងសូមប្រកាសបើកសិក្ខាសាលាស្តីពីការផ្សព្វផ្សាយអំពីគោលការណ៍ណែនាំស្តីពីការប្រើប្រាស់ទម្រង់របាយការណ៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប្រព័ន្ធលំហូររបាយការណ៍ក្រោមក្របខ័ណ្ឌផែនការអនុវត្តរយៈពេលបី ឆ្នាំដំបូង (២០១១-២០១៣) ចាប់ពីពេលនេះតទៅ។

**សូមអរគុណ !**